ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥២ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ជូនចំពោះ ឯកឧត្តម និងអស់លោក ចំនួន ០៧ រូប ៥៣៧

១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥៣ ស្តីពីការតែងតាំងឯកឧត្តម ទ្រាំ សុធមង្គល ជាទីប្រឹក្សាអមអាជ្ញាធរមីនកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៥៣៨

១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥៤ ស្តីពីការតែងតាំងឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សាអមក្រុមប្រឹក្សាភិបាលបជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ៥៣៩

២០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥៨ ស្តីពីការតែងតាំងជំនួយការឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជំនួយការងារនាយករដ្ឋមន្ត្រី អំពីការងារសាធារណៈការ និងដឹកជញ្ជូន វិនិយោគ និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ០២ រូប ៥៤០

២០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥៩ ស្តីពីការតែងតាំងឥស្សរជនចំនួន ០៦ រូប ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៥៤១

២០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦០ ស្តីពីការតែងតាំងឯកឧត្តម **អន សុផាណារ៉ា** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការវិនិយោគកម្ពុជា - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៥៤២

២២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៦១ ស្តីពីការបញ្ចប់តំណែង នាយឧត្តមសេនីយ៍ **កែ គីមយ៉ាន** ពីអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងត្រូវបានតែងតាំងមុខតំណែងជូននាយទាហានជាន់ខ្ពស់ចំនួន ០៨ រូប ៥៤៣


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


២៩-០១-២០០៩ -អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ ៥៤៥

៣០-០១-២០០៩ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ ៥៥៦
៣០-០១-២០០៩ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៥៥៩
២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៦២
២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦៣
២៨-០១-២០០៩ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពីការកែសម្រួលភារកិច្ច តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៦៥
២៨-០១-២០០៩ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៥៦៧
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦៨
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៦៩
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ៥៧០
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ៥៧១
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពីការផ្ទេរ តែងតាំង និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៧២
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៧៤
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៧៥
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៧៦
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ៥៧៧
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ៥៧៨
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៧៩
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៨១
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពីការតែងតាំងសមាជិក អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ៥៨៣
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៨៤
២៩-០១-២០០៩ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៨៥

## ២-សេចក្តីសំរេច

២៨-០១-២០០៩ -សេចក្តីសំរេចលេខ ០៧ សសរ ស្តីពីការបង្កើតក្រុមការងារពិសេសដើម្បីសម្របសម្រួល និងជំរុញ ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងដំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែក នៃតំបន់ឆ្នេរហាវ៉ៃ ៥៨៦

៣០-០១-២០០៩ -សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ក្រុមហ៊ុន UNION Development Co.,Ltd ខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍន៍នៅតាមតំបន់ការពារធម្មជាតិទូទាំងប្រទេស ៥៨៩

## ៣-សារាចរណែនាំ

៣០-០១-២០០៩ -សារាចរណែនាំលេខ ០២ សរណន ស្តីពីវិធានការធានាស្ថេរភាព បរិមាណម្ហូបអាហារនៅលើទីផ្សារ និងការនាំចេញស្រូវ-អង្ករទៅក្រៅប្រទេស ៥៩២

# III-ភាគខាងបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គ្រេន ហ្គោលដេន** ៥៩៤

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូស៊ើន** ៥៩៦

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធនាគារ " អូ អេស ខេ ឥណ្ឌូនេសា "** ៥៩៨

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៤០ ពណ.ចបព ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **យូ អេ អេស ហ្វាម៉ាស៊ូធីខល ភីធីអ៊ីវ៉ាយ អិលធីឌី** " ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅប្រទេសអូស្ត្រាលី ៦០០

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៤១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមខូ ស្ពេសល អេខូណាមិក ហ្សូន** ៦០១

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៤២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីលលេម៉ា ហូលឌីង ខូ អិលធីឌី** ៦០៣
១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៤៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូឌិន ម៉ាញ ម៉ាឃីត** ៦០៥
១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៤៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីកធីណាស ខូ អិលធីឌី** ៦០៧

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនចំពោះ :
១-ឯកឧត្តម ហេង ហាក់
២-ឯកឧត្តម ស៊ុំ សំណាង

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនចំពោះ :
១-ឯកឧត្តម គុយ ប៊ុនសន
២-ឯកឧត្តម ហ៊ុយ ហឿន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ :
១-លោក ឈឹម នី ៤-លោក គីម សារិន
២-លោក មុំ សាមាន ៥-លោក ជី ឈៀង
៣-លោក ម៉ាន់ ហាំ ៦-លោក សំ សៀក

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

៣៧៧.០៩០១.០៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើត អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពី វិសោធនកម្ម មាត្រា ៤, មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម ព្រំ សុភមង្គល ជាទីប្រឹក្សាអមអាជ្ញាធរមីនកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បរ.ល.០១០១.០៥៣

លេខ : ៥០ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

...ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩

...រាជរដ្ឋាភិបាល

ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៨៥ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៧៨ ស្តីពីវិសោធនកម្មមាត្រា ៨, ៩ និង ១១ នៃជំពូកទី ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំង :

១- ឯកឧត្តម ឆេង សារឿន ជាទីប្រឹក្សាអមក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម ឯក បូលីន ជាទីប្រឹក្សាអមក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបាន សម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩០១.០៥៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩*

លេខៈ ៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ចិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងជំនួយការ ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជួយការងារនាយករដ្ឋមន្ត្រី អំពីការងារសាធារណការ និងដឹកជញ្ជូន វិនិយោគ និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ស៊ុយ សាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម បុង ប៊ុនហួន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

៣៧.០៩០១.០៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩

លេខ : ៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០០៩

[illegible]រាជរដ្ឋាភិបាល

ឃុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០៦ រូប ជាទីប្រឹក្សាអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម ហ៊ូ វុឌ្ឍី មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម អ៊ុក សមវិទ្យា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៣-ឯកឧត្តម រ័ត្ន ប៊ុនឡា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៤-ឯកឧត្តម ពីប អឿន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៥-ឯកឧត្តម ម៉ែន សុចិត្រ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៦-ឯកឧត្តម ជូរ អៀងលី មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

ព.ល. ០១០៩.០៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩

លេខ: ៥៨ ច.ល
...មុខបែក
រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ មករា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៦០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម អ៊ន សុជាណារ៉ា ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការវិនិយោគកម្ពុជា-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

*ពរេ.០៩០១.០៦០*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៦០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ចំនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់តំណែង នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** អត្តលេខ ០០០០០៨ ពីអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** ត្រូវបានតែងតាំងមុខតំណែងជូននាយទាហានជាន់ខ្ពស់ចំនួន ០៨ រូប ដូចមានរាយនាមខាងក្រោម :

- នាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អត្តលេខ ០០០០១៧ ជាអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- នាយឧត្តមសេនីយ៍ **ពន់ គឹម** អត្តលេខ ០០៤២៨២ ជាអគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជានាយសេនាធិការចំរុះ បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- នាយឧត្តមសេនីយ៍ **មាស សុភា** អត្តលេខ ០០០០១៦ ជាអគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក
- ឧត្តមសេនីយ៍ឯក **មល់ រឿប** អត្តលេខ ០០០០៤៣ ជាអគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឧត្តមសេនីយ៍ឯក **ជា តារា** អត្តលេខ ០០០១៨៣ ជាអគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឧត្តមសេនីយ៍ឯក **ហ៊ីង ប៊ុនហៀង** អត្តលេខ ០០០៤៤៤ ជាអគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឧត្តមសេនីយ៍ឯក **សៅ សុខា** អត្តលេខ ០០០១០៥ ជាអគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឧត្តមនាវីឯក **អ៊ុង សំខាន់** អត្តលេខ ០០០០៤២ ជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៣ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស.រក.០១០៩.០៦១*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៥៧ ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០០៩**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១ .-** ត្រូវបានកំណត់ចំនួនគណៈអភិបាលរាជធានី និងគណៈអភិបាលខេត្តនីមួយៗ អនុលោមតាមមាត្រា ១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន ដូចខាងក្រោម ÷

| | | |
|---|---|---|
| ០១-រាជធានីភ្នំពេញ | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០២-ខេត្ត កំពង់ចាម | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០៣-ខេត្ត កណ្តាល | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០៤-ខេត្ត បាត់ដំបង | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០៥-ខេត្ត ព្រៃវែង | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០៦-ខេត្ត សៀមរាប | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០៧-ខេត្ត តាកែវ | មានចំនួនគណៈអភិបាល | ៧ នាក់ |
| ០៨-ខេត្ត បន្ទាយមានជ័យ | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ០៩-ខេត្ត កំពង់ស្ពឺ | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១០-ខេត្ត កំពង់ធំ | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១១-ខេត្ត កំពង់ឆ្នាំង | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១២-ខេត្ត កំពត | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១៣-ខេត្ត ស្វាយរៀង | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១៤-ខេត្ត ពោធិ៍សាត់ | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១៥-ខេត្ត ក្រចេះ | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១៦-ខេត្ត ព្រះសីហនុ | មានចំនួនគណៈអភិបាល | ៦ នាក់ |
| ១៧-ខេត្ត ព្រះវិហារ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១៨-ខេត្ត រតនគិរី | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១៩-ខេត្ត កោះកុង | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ២០-ខេត្ត ស្ទឹងត្រែង | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ២១-ខេត្ត ឧត្តរមានជ័យ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ២២-ខេត្ត មណ្ឌលគិរី | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ២៣-ខេត្ត កែប | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ២៤-ខេត្ត ប៉ៃលិន | មានចំនួនគណៈអភិបាល | ៥ នាក់ |

**មាត្រា ២ .-** ត្រូវបានកំណត់ចំនួនគណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌនីមួយៗ អនុលោមតាមមាត្រា១៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន ដូចខាងក្រោម ÷

**០១.<u>រាជធានីភ្នំពេញ</u>**

| | | |
|---|---|---|
| ០១-ខណ្ឌ ដង្កោ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ០២-ខណ្ឌ មានជ័យ | - ដ - | ៥ នាក់ |
| ០៣-ខណ្ឌ ចំការមន | - ដ - | ៥ នាក់ |
| ០៤-ខណ្ឌ ទួលគោក | - ដ - | ៥ នាក់ |
| ០៥-ខណ្ឌ ឫស្សីកែវ | - ដ - | ៥ នាក់ |
| ០៦-ខណ្ឌ ដូនពេញ | - ដ - | ៥ នាក់ |
| ០៧-ខណ្ឌ ៧ មករា | - ដ - | ៥ នាក់ |
| ០៨-ខណ្ឌ សែនសុខ | - ដ - | ៥ នាក់ |

**០២.<u>ខេត្ត កំពង់ចាម</u>**

| | | |
|---|---|---|
| ០៩- ស្រុក ត្បូងឃ្មុំ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១០- ស្រុក ព្រៃឈរ | - ដ - | ៥ នាក់ |
| ១១- ស្រុក មេមត់ | - ដ - | ៥ នាក់ |
| ១២- ស្រុក ចំការលើ | - ដ - | ៥ នាក់ |
| ១៣- ស្រុក ពញាក្រែក | - ដ - | ៥ នាក់ |
| ១៤- ស្រុក ស្រីសន្ធរ | - ដ - | ៥ នាក់ |
| ១៥- ស្រុក ស្ទឹងត្រង់ | - ដ - | ៥ នាក់ |
| ១៦- ស្រុក កំពង់សៀម | - ដ - | ៥ នាក់ |
| ១៧- ស្រុក បាធាយ | - ដ - | ៥ នាក់ |
| ១៨- ស្រុក កងមាស | - ដ - | ៥ នាក់ |
| ១៩- ស្រុក ក្រូចឆ្មារ | - ដ - | ៥ នាក់ |

| | | |
|---|---|---|
| ២០- ស្រុក ជើងព្រៃ | - ដ - | ៥ នាក់ |
| ២១- ស្រុក តំបែរ | - ដ - | ៥ នាក់ |
| ២២- ស្រុក អូររាំងឪ | - ដ - | ៥ នាក់ |
| ២៣- ស្រុក កោះសូទិន | - ដ - | ៥ នាក់ |
| ២៤- ក្រុង កំពង់ចាម | - ដ - | ៥ នាក់ |
| ២៥- ក្រុងសួង | - ដ - | ៤ នាក់ |

### ០៣.ខេត្ត កណ្តាល

| | | |
|---|---|---|
| ២៦-ស្រុក កៀនស្វាយ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ២៧-ស្រុក ស្អាង | - ដ - | ៥ នាក់ |
| ២៨-ស្រុក កោះធំ | - ដ - | ៥ នាក់ |
| ២៩-ស្រុក ខ្សាច់កណ្តាល | - ដ - | ៥ នាក់ |
| ៣០-ស្រុក ពញាឮ | - ដ - | ៥ នាក់ |
| ៣១-ស្រុក មុខកំពូល | - ដ - | ៥ នាក់ |
| ៣២-ស្រុក អង្គស្នួល | - ដ - | ៥ នាក់ |
| ៣៣-ស្រុក កណ្តាលស្ទឹង | - ដ - | ៥ នាក់ |
| ៣៤-ស្រុក ល្វាឯម | - ដ - | ៥ នាក់ |
| ៣៥-ក្រុង តាខ្មៅ | - ដ - | ៥ នាក់ |
| ៣៦-ស្រុក លើកដែក | - ដ - | ៤ នាក់ |

### ០៤.ខេត្ត បាត់ដំបង

| | | |
|---|---|---|
| ៣៧- ស្រុក ថ្មគោល | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ៣៨- ស្រុក មោងឫស្សី | - ដ - | ៥ នាក់ |
| ៣៩- ស្រុក សង្កែ | - ដ - | ៥ នាក់ |
| ៤០- ស្រុក បាណន់ | - ដ - | ៥ នាក់ |
| ៤១- ស្រុក បវេល | - ដ - | ៥ នាក់ |
| ៤២- ស្រុក ឯកភ្នំ | - ដ - | ៥ នាក់ |
| ៤៣- ក្រុង បាត់ដំបង | - ដ - | ៥ នាក់ |

| | | |
|---|---|---|
| ៤៤- ស្រុក ភ្នំព្រឹក | - ដ - | ៤ នាក់ |
| ៤៥- ស្រុក កំរៀង | - ដ - | ៤ នាក់ |
| ៤៦- ស្រុក រតនមណ្ឌល | - ដ - | ៤ នាក់ |
| ៤៧- ស្រុក សំឡូត | - ដ - | ៤ នាក់ |
| ៤៨- ស្រុក គាស់ក្រឡ | - ដ - | ៤ នាក់ |
| ៤៩- ស្រុក រុក្ខគិរី | - ដ - | ៤ នាក់ |
| ៥០- ស្រុក សំពៅលូន | - ដ - | ៣ នាក់ |

## ០៥.ខេត្ត ព្រៃវែង

| | | |
|---|---|---|
| ៥១-ស្រុក កំពង់ត្របែក | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ៥២-ស្រុក ពារាំង | - ដ - | ៥ នាក់ |
| ៥៣-ស្រុក ព្រះស្តេច | - ដ - | ៥ នាក់ |
| ៥៤-ស្រុក ស្វាយអន្ទរ | - ដ - | ៥ នាក់ |
| ៥៥-ស្រុក មេសាង | - ដ - | ៥ នាក់ |
| ៥៦-ស្រុក បាភ្នំ | - ដ - | ៥ នាក់ |
| ៥៧-ស្រុក ស៊ីធរកណ្តាល | - ដ - | ៥ នាក់ |
| ៥៨-ស្រុក កញ្ច្រៀច | - ដ - | ៥ នាក់ |
| ៥៩-ស្រុក ពាមជរ | - ដ - | ៥ នាក់ |
| ៦០-ស្រុក កំចាយមារ | - ដ - | ៤ នាក់ |
| ៦១-ស្រុក ពាមរក៍ | - ដ - | ៤ នាក់ |
| ៦២-ស្រុក កំពង់លាវ | - ដ - | ៤ នាក់ |
| ៦៣-ក្រុង ព្រៃវែង | - ដ - | ៤ នាក់ |

## ០៦.ខេត្ត សៀមរាប

| | | |
|---|---|---|
| ៦៤-ស្រុក ជីក្រែង | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ៦៥-ស្រុក ពួក | - ដ - | ៥ នាក់ |
| ៦៦-ស្រុក សូទ្រនិគម | - ដ - | ៥ នាក់ |
| ៦៧-ស្រុក ប្រាសាទបាគង | - ដ - | ៥ នាក់ |
| ៦៨-ស្រុក ក្រឡាញ់ | - ដ - | ៤ នាក់ |

| | | |
|---|---|---|
| ៦៩-ស្រុក អង្គរជុំ | - ដ - | ៤ នាក់ |
| ៧០-ក្រុង សៀមរាប | - ដ - | ៤ នាក់ |
| ៧១-ស្រុក បន្ទាយស្រី | - ដ - | ៤ នាក់ |
| ៧២-ស្រុក ស្រីស្នំ | - ដ - | ៤ នាក់ |
| ៧៣-ស្រុក ស្វាយលើ | - ដ - | ៤ នាក់ |
| ៧៤-ស្រុក វ៉ារិន | - ដ - | ៤ នាក់ |
| ៧៥-ស្រុក អង្គរធំ | - ដ - | ៣ នាក់ |

## ០៧.ខេត្ត បន្ទាយមានជ័យ

| | | |
|---|---|---|
| ៧៦- ស្រុក មង្គលបូរី | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ៧៧- ស្រុក ព្រះនេត្រព្រះ | - ដ - | ៥ នាក់ |
| ៧៨- ក្រុង សិរីសោភ័ណ | - ដ - | ៥ នាក់ |
| ៧៩- ស្រុក អូរជ្រៅ | - ដ - | ៤ នាក់ |
| ៨០- ស្រុក ភ្នំស្រុក | - ដ - | ៤ នាក់ |
| ៨១- ស្រុក ស្វាយចេក | - ដ - | ៤ នាក់ |
| ៨២- ក្រុង ប៉ោយប៉ែត | - ដ - | ៤ នាក់ |
| ៨៣- ស្រុក ថ្មពួក | - ដ - | ៤ នាក់ |
| ៨៤- ស្រុក ម៉ាឡៃ | - ដ - | ៤ នាក់ |

## ០៨.ខេត្ត តាកែវ

| | | |
|---|---|---|
| ៨៥-ស្រុក បាទី | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ៨៦-ស្រុក ត្រាំកក់ | - ដ - | ៥ នាក់ |
| ៨៧-ស្រុក សំរោង | - ដ - | ៥ នាក់ |
| ៨៨-ស្រុក ទ្រាំង | - ដ - | ៥ នាក់ |
| ៨៩-ស្រុក គិរីវង់ | - ដ - | ៥ នាក់ |
| ៩០-ស្រុក ព្រៃកប្បាស | - ដ - | ៥ នាក់ |
| ៩១-ក្រុង ដូនកែវ | - ដ - | ៥ នាក់ |
| ៩២-ស្រុក អង្គរបូរី | - ដ - | ៤ នាក់ |
| ៩៣-ស្រុក កោះអណ្តែត | - ដ - | ៤ នាក់ |
| ៩៤-ស្រុក បុរីជលសារ | - ដ - | ៤ នាក់ |

## ០៩.ខេត្ត កំពង់ស្ពឺ

| | | |
|---|---|---|
| ៩៥- ស្រុក បសេដ្ឋ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ៩៦- ស្រុក គងពិសី | - ដ - | ៥ នាក់ |
| ៩៧- ស្រុក ឧដុង្គ | - ដ - | ៥ នាក់ |
| ៩៨- ស្រុក ភ្នំស្រួច | - ដ - | ៥ នាក់ |
| ៩៩- ស្រុក សំរោងទង | - ដ - | ៥ នាក់ |
| ១០០- ក្រុង ច្បារមន | - ដ - | ៥ នាក់ |
| ១០១- ស្រុក ថ្ពង | - ដ - | ៤ នាក់ |
| ១០២- ស្រុក ឱរ៉ាល់ | - ដ - | ៤ នាក់ |

## ១០.ខេត្ត កំពង់ធំ

| | | |
|---|---|---|
| ១០៣- ស្រុក បារាយណ៍ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១០៤- ស្រុក ស្ទោង | - ដ - | ៥ នាក់ |
| ១០៥- ស្រុក កំពង់ស្វាយ | - ដ - | ៥ នាក់ |
| ១០៦- ស្រុក សន្ទុក | - ដ - | ៥ នាក់ |
| ១០៧- ក្រុង ស្ទឹងសែន | - ដ - | ៥ នាក់ |
| ១០៨- ស្រុក ប្រាសាទបល្ល័ង្គ | - ដ - | ៤ នាក់ |
| ១០៩- ស្រុក សណ្តាន់ | - ដ - | ៤ នាក់ |
| ១១០- ស្រុក ប្រាសាទសំបូរ | - ដ - | ៤ នាក់ |

## ១១.ខេត្ត កំពង់ឆ្នាំង

| | | |
|---|---|---|
| ១១១- ស្រុក រលាប្អៀរ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១១២- ស្រុក កំពង់ត្រឡាច | - ដ - | ៥ នាក់ |
| ១១៣- ស្រុក សាមគ្គីមានជ័យ | - ដ - | ៥ នាក់ |
| ១១៤- ស្រុក កំពង់លែង | - ដ - | ៤ នាក់ |
| ១១៥- ស្រុក បរិបូណ៌ | - ដ - | ៤ នាក់ |
| ១១៦- ស្រុក ទឹកផុស | - ដ - | ៤ នាក់ |
| ១១៧- ក្រុង កំពង់ឆ្នាំង | - ដ - | ៤ នាក់ |
| ១១៨- ស្រុក ជលគីរី | - ដ - | ៤ នាក់ |

**១២.ខេត្ត កំពត**

| | | |
|---|---|---|
| ១១៩- ស្រុក ទឹកឈូ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១២០- ស្រុក កំពង់ត្រាច | - ដ - | ៥ នាក់ |
| ១២១- ស្រុក ឈូក | - ដ - | ៥ នាក់ |
| ១២២- ស្រុក បន្ទាយមាស | - ដ - | ៥ នាក់ |
| ១២៣- ស្រុក អង្គរជ័យ | - ដ - | ៥ នាក់ |
| ១២៤- ស្រុក ដងទង់ | - ដ - | ៤ នាក់ |
| ១២៥- ស្រុក ជុំគិរី | - ដ - | ៤ នាក់ |
| ១២៦- ក្រុង កំពត | - ដ - | ៤ នាក់ |

**១៣.ខេត្ត ស្វាយរៀង**

| | | |
|---|---|---|
| ១២៧-ស្រុក រមាសហែក | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១២៨-ស្រុក ស្វាយជ្រំ | - ដ - | ៥ នាក់ |
| ១២៩-ក្រុង ស្វាយរៀង | - ដ - | ៥ នាក់ |
| ១៣០-ស្រុក កំពង់រោទិ៍ | - ដ - | ៤ នាក់ |
| ១៣១-ស្រុក រំដួល | - ដ - | ៤ នាក់ |
| ១៣២-ស្រុក ស្វាយទាប | - ដ - | ៤ នាក់ |
| ១៣៣-ក្រុង បាវិត | - ដ - | ៤ នាក់ |
| ១៣៤-ស្រុក ចន្ទ្រា | - ដ - | ៤ នាក់ |

**១៤.ខេត្ត ពោធិ៍សាត់**

| | | |
|---|---|---|
| ១៣៥-ស្រុក បាកាន | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១៣៦-ស្រុក ក្រគរ | - ដ - | ៥ នាក់ |
| ១៣៧-ក្រុង ពោធិ៍សាត់ | - ដ - | ៥ នាក់ |
| ១៣៨-ស្រុក ភ្នំក្រវាញ | - ដ - | ៤ នាក់ |
| ១៣៩-ស្រុក កណ្ដៀង | - ដ - | ៤ នាក់ |
| ១៤០-ស្រុក វាលវែង | - ដ - | ៣ នាក់ |

**១៥.ខេត្ត កោះកុង**

| | | |
|---|---|---|
| ១៤១-ក្រុង ខេមរភូមិន្ទ | មានចំនួនគណៈអភិបាល | ៤ នាក់ |

| | | |
|---|---|---|
| ១៤២-ស្រុក បទុមសាគរ | - ដ - | ៣ នាក់ |
| ១៤៣-ស្រុក ស្រែអំបិល | - ដ - | ៣ នាក់ |
| ១៤៤-ស្រុក មណ្ឌលសីមា | - ដ - | ៣ នាក់ |
| ១៤៥-ស្រុក គិរីសាគរ | - ដ - | ៣ នាក់ |
| ១៤៦-ស្រុក កោះកុង | - ដ - | ៣ នាក់ |
| ១៤៧-ស្រុក ថ្មបាំង | - ដ - | ៣ នាក់ |

**១៦.ខេត្ត ក្រចេះ**

| | | |
|---|---|---|
| ១៤៨-ស្រុក ព្រែកប្រសព្វ | មានចំនួនគណៈអភិបាល | ៤ នាក់ |
| ១៤៩-ស្រុក ឆ្លូង | - ដ - | ៤ នាក់ |
| ១៥០-ស្រុក សំបូរ | - ដ - | ៤ នាក់ |
| ១៥១-ស្រុក ស្នួល | - ដ - | ៤ នាក់ |
| ១៥២-ស្រុក ចិត្របុរី | - ដ - | ៤ នាក់ |
| ១៥៣-ក្រុង ក្រចេះ | - ដ - | ៤ នាក់ |

**១៧.ខេត្ត ព្រះវិហារ**

| | | |
|---|---|---|
| ១៥៤-ស្រុក រវៀង | មានចំនួនគណៈអភិបាល | ៤ នាក់ |
| ១៥៥-ក្រុង ព្រះវិហារ | - ដ - | ៤ នាក់ |
| ១៥៦-ស្រុក ជាំក្សាន្ត | - ដ - | ៣ នាក់ |
| ១៥៧-ស្រុក គូលែន | - ដ - | ៣ នាក់ |
| ១៥៨-ស្រុក ជ័យសែន | - ដ - | ៣ នាក់ |
| ១៥៩-ស្រុក សង្គមថ្មី | - ដ - | ៣ នាក់ |
| ១៦០-ស្រុក ត្បែងមានជ័យ | - ដ - | ៣ នាក់ |
| ១៦១-ស្រុក ឆែប | - ដ - | ៣ នាក់ |

**១៨.ខេត្ត រតនគិរី**

| | | |
|---|---|---|
| ១៦២-ក្រុង បានលុង | មានចំនួនគណៈអភិបាល | ៤ នាក់ |
| ១៦៣-ស្រុក លំផាត់ | - ដ - | ៣ នាក់ |
| ១៦៤-ស្រុក អូរជុំ | - ដ - | ៣ នាក់ |
| ១៦៥-ស្រុក វើនសៃ | - ដ - | ៣ នាក់ |

| | | |
|---|---|---|
| ១៦៦-ស្រុក បរកែវ | - ដ - | ៣ នាក់ |
| ១៦៧-ស្រុក កូនមុំ | - ដ - | ៣ នាក់ |
| ១៦៨-ស្រុក អណ្ដូងមាស | - ដ - | ៣ នាក់ |
| ១៦៩-ស្រុក អូរយ៉ាដាវ | - ដ - | ៣ នាក់ |
| ១៧០-ស្រុក តាវែង | - ដ - | ៣ នាក់ |

## ១៩.ខេត្ត ព្រះសីហនុ

| | | |
|---|---|---|
| ១៧១-ស្រុក ព្រៃនប់ | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១៧២-ក្រុង ព្រះសីហនុ | - ដ - | ៥ នាក់ |
| ១៧៣-ស្រុក កំពង់សីលា | - ដ - | ៣ នាក់ |
| ១៧៤-ស្រុក ស្ទឹងហាវ | - ដ - | ៣ នាក់ |

## ២០.ខេត្ត ស្ទឹងត្រែង

| | | |
|---|---|---|
| ១៧៥-ក្រុង ស្ទឹងត្រែង | មានចំនួនគណៈអភិបាល | ៤ នាក់ |
| ១៧៦-ស្រុក ថាឡាបរិវ៉ាត់ | - ដ - | ៤ នាក់ |
| ១៧៧-ស្រុក សៀមប៉ាង | - ដ - | ៣ នាក់ |
| ១៧៨-ស្រុក សេសាន | - ដ - | ៣ នាក់ |
| ១៧៩-ស្រុក សៀមបូក | - ដ - | ៣ នាក់ |

## ២១.ខេត្ត ឧត្ដរមានជ័យ

| | | |
|---|---|---|
| ១៨០-ក្រុង សំរោង | មានចំនួនគណៈអភិបាល | ៥ នាក់ |
| ១៨១-ស្រុក បន្ទាយអំពិល | - ដ - | ៤ នាក់ |
| ១៨២-ស្រុក អន្លង់វែង | - ដ - | ៤ នាក់ |
| ១៨៣-ស្រុក ត្រពាំងប្រាសាទ | - ដ - | ៤ នាក់ |
| ១៨៤-ស្រុក ចុងកាល់ | - ដ - | ៣ នាក់ |

## ២២.ខេត្ត មណ្ឌលគិរី

| | | |
|---|---|---|
| ១៨៥-ក្រុង សែនមនោរម្យ | មានចំនួនគណៈអភិបាល | ៣ នាក់ |
| ១៨៦-ស្រុក កែវសីមា | - ដ - | ៣ នាក់ |
| ១៨៧-ស្រុក កោះញែក | - ដ - | ៣ នាក់ |

| | | |
|---|---|---|
| ១៨៨-ស្រុក ពេជ្រាដា | - ដ - | ៣ នាក់ |
| ១៨៩-ស្រុក អូររាំង | - ដ - | ៣ នាក់ |

**២៣.ខេត្ត ប៉ៃលិន**

| | | |
|---|---|---|
| ១៩០-ក្រុង ប៉ៃលិន | មានចំនួនគណៈអភិបាល | ៤ នាក់ |
| ១៩១-ស្រុក សាលាក្រៅ | - ដ - | ៤ នាក់ |

**២៤.ខេត្ត កែប**

| | | |
|---|---|---|
| ១៩២-ស្រុក ដំណាក់ចង្អើរ | មានចំនួនគណៈអភិបាល | ៣ នាក់ |
| ១៩៣-ក្រុង កែប | - ដ - | ៣ នាក់ |

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការនៃរាជរដ្ឋាភិបាល*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ដែលមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល មានតួនាទីជាសេនាធិការជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការត្រួតពិនិត្យការបំពេញតួនាទី និងភារកិច្ចរបស់មន្ត្រីក្រោមឱវាទក្រសួងមហាផ្ទៃ ធ្វើអធិការកិច្ចលើបណ្តាអង្គភាពនានាស្ថិតក្នុងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ និងទទួលពិនិត្យ សិក្សា ស្រាវជ្រាវ និងលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យ សំរេចលើវិវាទរដ្ឋបាល ពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធជាមួយមន្ត្រីរាជការក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ៣** : អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល មានភារកិច្ចដូចខាងក្រោម :

- ធ្វើអធិការកិច្ចនៅតាមអង្គភាពថ្នាក់កណ្តាល និង ថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ទាំងផ្នែករដ្ឋបាលស៊ីវិល និងនគរបាល តាមកំណត់នៃឆ្នាំនីមួយៗ ។
- ត្រួតពិនិត្យសកម្មភាពការងារ និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាល និងមន្ត្រីនគរបាលនៅថ្នាក់កណ្តាល និងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចំណុះក្រសួងមហាផ្ទៃ ក្នុងការអនុវត្តផែនការសកម្មភាពរបស់ក្រសួងមហាផ្ទៃ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងច្បាប់រដ្ឋ ។
- សហការជាមួយអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ក្នុងការលើកសំណើជូនរដ្ឋមន្ត្រី ដើម្បីពិនិត្យ សំរេចផ្អាកការងារបណ្តោះអាសន្ន ចំពោះមន្ត្រីដែលពាក់ព័ន្ធកំហុសធ្ងន់ធ្ងរ ដើម្បីទុកឱកាសធ្វើការអង្កេតស្រាវជ្រាវ ។
- ក្នុងករណីពិនិត្យ និងស្រាវជ្រាវរកឃើញថា មន្ត្រីនានាស្ថិតក្នុងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ បានប្រព្រឹត្តនូវកំហុសធ្ងន់ធ្ងរ ដែលត្រូវស្នើអនុវត្តទណ្ឌកម្មខាងវិន័យ អគ្គាធិការដ្ឋានត្រូវពិភាក្សាជាមួយអង្គភាពសាមី ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី និងស្នើសុំយោបល់ពិនិត្យ សំរេចទៅលើរូបភាពទណ្ឌកម្មខាងវិន័យ ដែលនឹងត្រូវយកមកអនុវត្ត ឱ្យបានស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ។
- សហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃទាំងនៅថ្នាក់កណ្តាល និង ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីប្រមូលពត៌មានដែលទាក់ទងដល់ការធ្វើអង្កេត ស្រាវជ្រាវ និងធ្វើអធិការកិច្ច ។
- ណែនាំ និងបណ្តុះបណ្តាលដល់មន្ត្រីអគ្គាធិការដ្ឋាន លើជំនាញអធិការកិច្ចក្នុងការតាមដាន និងជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានា ដែលរាជរដ្ឋាភិបាល និងក្រសួងបានដាក់ចេញ ។
- បន្ទាប់ពីបានទទួលបណ្តឹងតវ៉ា ឬបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋដល់មន្ត្រីក្រោមឱវាទក្រសួងមហាផ្ទៃ អគ្គាធិការដ្ឋានត្រូវពិនិត្យ សិក្សា ស្រាវជ្រាវ និងលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសំរេចទៅលើវិធានការនានាស្របទៅតាមគោលការណ៍ច្បាប់ ។
- ចូលរួមពិនិត្យ ស្រាវជ្រាវ និងដោះស្រាយបណ្តឹងនានាជាមួយគណៈកម្មាការចំរុះអន្តរក្រសួង ក្នុងករណីមានការស្នើសុំ ។
- បូកសរុបលទ្ធផលការងារ គ្រប់គ្រងឯកសារ ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់អគ្គាធិការដ្ឋាន តាមការកំណត់របស់ក្រសួង ។
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា ៤** : អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងមួយចំនួន ជាជំនួយការ ។

អគ្គាធិការត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬមន្ត្រីនគរបាលជាតិដែលមានឋានន្តរសក្តិជាឧត្តមសេនីយ៍ ។

អគ្គាធិការរងត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ចាប់ពី វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬពីក្នុងចំណោមមន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិជាឧត្តមសេនីយ៍ ។

**មាត្រា ៥** : រចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានកំណត់ដូចខាងក្រោម :

- លេខាធិការដ្ឋាន
- អធិការដ្ឋានអធិការកិច្ច កិច្ចការនយោបាយរដ្ឋបាល
- អធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនយោបាយរដ្ឋបាល
- អធិការដ្ឋានអធិការកិច្ច កិច្ចការនគរបាល
- អធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនគរបាល ។

**មាត្រា ៦** : អធិការដ្ឋានចំណុះអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានដឹកនាំដោយអធិការមួយរូប និងមានអធិការរងមួយចំនួន ជាជំនួយការ ។

លេខាធិការដ្ឋាននៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើនឹងអធិការរង នៃអធិការដ្ឋានចំណុះអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល ។

អធិការត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ចាប់ពី វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬពីក្នុងចំណោមមន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិចាប់ពី វរសេនីយ៍ឯក ឡើងទៅ ។

អធិការរងត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ចាប់ពីអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬពីក្នុងចំណោមមន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិចាប់ពីវរសេនីយ៍ឯក ឡើងទៅ ។

**មាត្រា ៧** : តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់អធិការដ្ឋាន និង លេខាធិការដ្ឋាន នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៨** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៩
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ

## ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ៖

-ទីតាំងស្ថិតក្រោមការកាន់កាប់របស់ក្រសួងសាធារណការ និងដឹកជញ្ជូនចំនួន០២កន្លែង រួមមាន៖

.ទីតាំងមួយផ្នែកនៃនាយកដ្ឋានសម្ភារៈ ទំហំដី ៨.៣៧៤ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ ១៣៨ និង

ផ្លូវលេខ ១៤៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

.ទីតាំងសាខានាយកដ្ឋានសម្ភារៈក្រុងព្រះសីហនុទំហំដី១៤.៧០៥ ម៉ែត្រក្រឡា ស្ថិតនៅបណ្ដោយផ្លូវជាតិលេខ៤ មណ្ឌល១ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។

-ទីតាំងស្ថិតក្រោមការកាន់កាប់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ចំនួន ០៥ កន្លែង រួមមាន៖

.អគ្គនាយកដ្ឋានសុរិយោដី ទំហំដី១.១០៦ម៉ែត្រក្រឡា នៅផ្លូវលេខ១៦៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

.នាយកដ្ឋានភូមិសាស្ត្រ ទំហំដី៧៦៨ ម៉ែត្រក្រឡា នៅផ្លូវលេខ៦៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

.សហគ្រាសសំណង់ភ្នំពេញ ទំហំដី១៤៤.៥០ ម៉ែត្រក្រឡា នៅផ្លូវលេខ ២៥៩ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

.សហគ្រាសសិក្សាស្រាវជ្រាវ និង គូរប្លង់ ទំហំដី ២២០ ម៉ែត្រក្រឡា នៅផ្លូវប៉ាស្ទ័រ សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ ទំហំដី ១.៣០០ ម៉ែត្រក្រឡា នៅផ្លូវលេខ ៣២៨ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ទីតាំងដីបំរុងសំរាប់ចំណតរ៉ឺម៉ក និង ម៉ូតូ ខេត្តកំពត ទំហំ៣.២៤៨ម៉ែត្រក្រឡា ស្ថិតក្រោមការកាន់កាប់ របស់សាលាខេត្តកំពត។

-ទីតាំងសាលាឃុំស្វាយប៉ោ ស្រុកបាត់ដំបង មានទំហំដី ១៦០ ម៉ែត្រក្រឡា ដែលស្ថិតក្រោមការកាន់កាប់ របស់សាលាខេត្តបាត់ដំបង។

-ទីតាំងអាគារ២ល្វែង ដីទំហំ១៦២ម៉ែត្រក្រឡា ក្រោមការកាន់កាប់របស់សាលាខេត្តបាត់ដំបង។

**មាត្រា ២.-**

ការកត់ត្រាទ្រព្យសម្បត្តិថ្មីដែលទទួលបានពីការដោះដូរ ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងអប់រំ យុវជន និង កីឡា សាលាខេត្តបាត់ដំបង សាលាខេត្តកំពត និង មន្ទីរជំនាញពាក់ព័ន្ធ ស្របគោលការណ៍របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើឯកជនភាវូបនីយកម្ម។

**មាត្រា ៣.-**

ការបំពេញបែបបទធ្វើកម្មសិទ្ធិរបស់ភាគីឯកជនលើទីតាំងរបស់រដ្ឋ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អភិបាលខេត្តបាត់ដំបង អភិបាលខេត្តកំពត និង ប្រធានមន្ទីរជំនាញពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៩

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ ✓

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩៦..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា១ :** បំពាក់មេដាយ **មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូនសប្បុរសជន ក្លឹបសន្តិភាពអន្តរជាតិជប៉ុន ចំនួន ០២ រូប ដែលមានស្នាដៃចូលរួមសហការ លើវិស័យមនុស្សធម៌ ជាមួយកាកបាទក្រហមកម្ពុជា ដោយបានបរិច្ចាគទ្រព្យធនផ្ទាល់ខ្លួន ក្នុងការកសាងសាលារៀន អណ្តូងទឹកស្អាត ផ្តល់ទោចក្រយាន និងសម្ភារៈជាច្រើនទៀត ដើម្បីចូលរួមសហការក្នុងការងារមនុស្សធម៌ដ៏ស្ថិតស្ថាញ តាមរយៈកាកបាទក្រហមកម្ពុជា ដូចមានរាយនាមខាងក្រោម :

**១- Mr. AOYAMA KAORU**

**២- Mrs. AOYAMA RUMI**

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩*

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៩៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១ :** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ក្លឹបសន្តិភាពអន្តរជាតិជប៉ុន ចំនួន ០៩ រូប ដែលមានស្នាដៃចូលរួមសហការ លើវិស័យមនុស្សធម៌ ជាមួយកាកបាទក្រហមកម្ពុជា ដោយបានបរិច្ចាគទ្រព្យធនផ្ទាល់ខ្លួន ក្នុងការកសាងសាលារៀន អណ្តូងទឹកស្អាត ផ្តល់ទោចក្រយាន និងសម្ភារៈជាច្រើនទៀត ដើម្បីចូលរួមសហការក្នុងការងារមនុស្សធម៌ដ៏ស្និតស្នាញ តាមរយៈកាកបាទក្រហមកម្ពុជា ដូចមានរាយនាមខាងក្រោម :

**១- Mrs. IKAI KAZUKO**

**២- Mr. SHIMIZU TOSHIYUKI**

**៣- Mr. OKUDA SHOJI**

៤- Mrs. YASUDA HIDEO

៥- Ms. ONO YOKO

៦- Mr. NAGANUMA YUKO

៧- Mrs. KANDA TAKAKO

៨- Mr. SEIKI TAKADA

៩- Mr. TADEKA YOSHIO

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៧៨...អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការកែសម្រួលភារកិច្ច តែងតាំង និង ប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១ :** កែសម្រួលភារកិច្ចជូនលោក **ម៉ែន សារុម** បច្ចុប្បន្នប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា មកជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ។

**មាត្រា ២ :** តែងតាំងមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ១០ រូប ដូចមានរាយនាមខាងក្រោម :

១-លោក **អ៊ុក ម៉ាភារា** ជាប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

២-លោក **ម៉ែន ស៊ីផាន់** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន

៣-លោក **សេន សុវណ្ណ** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន

៤-លោក **ម៉ែន ខុង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម

៥-លោក **ស្រ៊ុន សុខុម** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម

៦-លោក **ហ៊ាន វណ្ណហាន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម

៧-លោក **ប៉ិច សុវណ្ណ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម

៨-លោក **ទ្រាន់ ជាតិថូ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម

៩-លោក **ទិន ឆាយ** ជាប្រធាននាយកដ្ឋានដំណាំស្រូវ

១០-លោក **នៅ វេនា** ជាប្រធាននាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ ។

**មាត្រា ៣ :** ប្រគល់ភារកិច្ចជូនលោកស្រី **អ៊ុង វណ្ណារី** ឱ្យបំពេញមុខងារជាប្រធានមន្ទីរពិសោធន៍ជាតិកសិកម្ម ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ មាត្រា ២ និង មាត្រា ៣ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ២៣២ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុងប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមុខតំណែងលោក **ថ្វី ណារិន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ ជាអភិបាលក្រុងប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

១១៦៧៨១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឃុន ជា** មេបញ្ជាការរងកងរាជអាវុធហត្ថ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ ឧបដ្ឋានសាលា បណ្ណាល័យ របង ខ្លោងទ្វារ ទិញដីចាក់បំពេញទីធ្លា ធ្វើផ្លូវចូលវត្ត និងសមិទ្ធផលផ្សេងៗជាច្រើនទៀត ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និង ខេត្តព្រៃវែង ចំណាយអស់ថវិកាសរុប ចំនួន ១៤៨.០០០ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានីភ្នំពេញ អភិបាលខេត្តកណ្តាល និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនកញ្ញា **ដោរ៉ក សុទ្ធា** មន្ត្រីក្របខ័ណ្ឌក្រសួងបរិស្ថាន ជាអភិបាលរងខេត្តកំពង់ឆ្នាំង ជំនួសលោកជំទាវ **កែ ច័ន្ទមុនី** ដែលបានទៅបំពេញភារកិច្ចថ្មី ។

**មាត្រា ២ :** កញ្ញា **ដោរ៉ក សុទ្ធា** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ..២០៥..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់ឱ្យលោក **ស៊ាន ឡេង** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៣ អភិបាលស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ចូលនិវត្តន៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៣.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់ឱ្យលោក **ស៊ឹម ស៊ីផុន** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ អភិបាលស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ចូលនិវត្តន៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២រូប នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ុន សុខលី** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលស្រុកពញាក្រែក ឱ្យទៅជាអភិបាលស្រុកត្បូងឃ្មុំ

២- លោក **អ៊ី សាឲាត់** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលស្រុកកងមាស ឱ្យទៅជាអភិបាលស្រុកក្រូចឆ្មារ ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ម៉ុង ហ៊ាង** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ជាអភិបាលស្រុកកងមាស ខេត្តកំពង់ចាម ។

**មាត្រា ៣ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឡុង ធារម** បំានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ២ ជាអភិបាលស្រុកពញាក្រែក ខេត្តកំពង់ចាម ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៨*

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ* ✓

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ឈូត បណ្ឌិត** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៩ ពីអភិបាលស្រុកចន្ទ្រា ឱ្យទៅជាអភិបាលក្រុងបាវិត នៃខេត្តស្វាយរៀង ។

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ខា យឿន** ឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ២ ជាអភិបាលស្រុកចន្ទ្រា នៃខេត្តស្វាយរៀង ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ជា សុខរិទ្ធ** ឋានន្តរស័ក្តិ ក្រមការដើមខ្សែ ថ្នាក់លេខ ១០ ជាអភិបាលក្រុងសួង នៃខេត្តកំពង់ចាម ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១០៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ពេជ ម៉ាឡៃ** ឋានន្តរស័ក្តិ នាយក្រមការ ថ្នាក់លេខ ៤ ជាអភិបាលស្រុករុក្ខគិរី នៃខេត្តបាត់ដំបង ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៨ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ឡឿង ខេង** ជា **ទីប្រឹក្សា** ស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំមន្ទីរអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្លាស់លោក **កែវ តក្កី** អគ្គទីប្រឹក្សា ស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំមន្ទីរអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩**

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១១០.អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់មេដាយ**មាស**ស្ថាបនាជាតិ ជូន សប្បុរសជន ក្នុង និង ក្រៅប្រទេស ចំនួន ០៧ គ្រឿង ដែលបានចូលរួមកសាងសមិទ្ធផលនានានៅ ក្នុងស្រុកបាណន់ និង ស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១- លោក **ម៉ៅ ថា** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចូលរួមកសាង ស្ពានយោល ភូមិប៉ៃឡាំ ឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ថវិកាចំនួន ១៥.០០០ ដុល្លារ ។

២- លោកស្រី **ចំនួ លីដា** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចូលរួមកសាង ស្ពានយោល ក្នុងភូមិប៉ៃឡាំ ឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ថវិកាចំនួន ១៥.០០០ ដុល្លារ ។

៣- លោក **ទឹត ញ៉ៀ** សប្បុរសជននៅក្នុងស្រុកបាណន់ បានបរិច្ចាកដីផ្លូវ និងចូលរួមកសាង ស្ពានយោល ភូមិប៉ៃឡាំ ឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ថវិកាចំនួន ១២.០០០ ដុល្លារ ។

៤- លោក **សយ សារ៉ាត** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចូលរួមកសាង ផ្លូវក្រាលគ្រួសក្រហម និងជីកស្រះទឹក០២កន្លែង ក្នុងភូមិប៉ៃឡាំ ឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ថវិកាចំនួន ១៥.១០០ ដុល្លារ ។

៥- លោក **ឈិន ម៉ិនឆឿន** សប្បុរសជននៅក្នុងស្រុកបាណន់ ចូលរួមកសាង ឧបដ្ឋានសាលា, សាលារៀន, និងបោត ភូមិប៉ៃឡាំ ឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ថវិកាចំនួន ១២,៥០០ ដុល្លារ ។

៦- ឧបាសិកា **ឡុង គីត** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចូលរួមកសាង កុដិថ្ម ០១ខ្នង និងសមិទ្ធិផលមួយចំនួនទៀតនៅក្នុងបរិវេណវត្ត**ដង្កោពេន** ក្នុងឃុំព្រៃខ្ពស់ ស្រុកបវេល ខេត្តបាត់ដំបង ថវិកាចំនួន ១៣,៣១៨ ដុល្លារ ។

៧- ទាយិកា **ថៃ សារ៉ាត** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចូលរួមកសាង កុដិថ្ម ០១ខ្នង និងសមិទ្ធិផលមួយចំនួនទៀតនៅក្នុងបរិវេណវត្ត**ដង្កោពេន** ក្នុងឃុំព្រៃខ្ពស់ ស្រុកបវេល ខេត្តបាត់ដំបង ថវិកាចំនួន ១៣,៣១៨ ដុល្លារ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបងត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និងមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីចំនួន ០២ រូប របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដូចមានរាយនាមខាងក្រោមៈ

១- លោក **ប៊ិន ប៊ុនធាត** ជាប្រធាននាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំ បន្ថែមលើមុខងារបច្ចុប្បន្ន។

២- លោក **សុន្ទ ធី** ជាប្រធាននាយកដ្ឋានបូកសរុបព័ត៌មានវិទ្យា និង ទំនាក់ទំនងសាធារណៈ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាជិក អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពី វិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពី ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-យោងតាមតំរូវការចាំបាច់របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំង **ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន** អគ្គស្នងការនគរបាលជាតិជាសមាជិកអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងមន្ត្រីដែលមានការពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងលោក **យឹម ម៉ុនឡុង** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ៣** : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១១៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតំរូវការការងារចាំបាច់

### សម្រេច

**មាត្រា១ៈ** ត្រូវបានតែងតាំង លោក **ជុំ សុជាវ៉ាត់** ជាទីប្រឹក្សាក្រសួងទេសចរណ៍ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល__ :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PSSD-1/23/2009

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៧...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារពិសេសដើម្បីសម្របសម្រួល និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹង ដំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យកែសំរួលលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមការងារពិសេស ដើម្បីសម្របសម្រួល និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងដំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ ដែលមានសមាសភាព ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- | ឯកឧត្តម សុខ ចិន្តា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- | ឯកឧត្តម នុត ណារ៉ាង រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- | ឯកឧត្តម ប្រាជ្ញ ស៊ុន រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៤- | ឯកឧត្តម ភោគ សុវណ្ណរិទ្ធ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦- | ឯកឧត្ត លឹម ស៊ីដេនីន រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៧- | ឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨- | ឯកឧត្តម សួស យ៉ារ៉ា អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- | ឯកឧត្តម ស្បោង សារ៉ាត អភិបាលខេត្តព្រះសីហនុ | សមាជិក |

**ប្រការ២** : ក្រុមការងារពិសេសនេះ មានតួនាទី និងភារកិច្ចដូចតទៅ :

- ចុះពិនិត្យជាក់ស្តែង និងជំរុញដោះស្រាយរាល់បញ្ហាដែលក្រុមហ៊ុនវិនិយោគជួបប្រទះក្នុងតំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ សំដៅសម្រួលការអភិវឌ្ឍន៍គំរោងនេះអោយដំណើរការទៅបានដោយរលូន និងមានប្រសិទ្ធភាព
- ធ្វើរបាយការណ៍ និងលើកសំណើសុំយោបល់ និងការសំរេចផ្ទាល់ជូនប្រមុខរាជរដ្ឋាភិបាល លើរាល់ករណីពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាដែលក្រុមហ៊ុនជួបប្រទះ។

**ប្រការ៣** : សមាជិកនៃក្រុមការងារពិសេស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ប្រធានក្រុមការងារមានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមផ្តល់មតិ និងដោះស្រាយបញ្ហា។ ក្រុមការងារពិសេសមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសមាសភាព ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៨ សសរ

# សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន UNION Development Co., Ltd ខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍន៍នៅតាមតំបន់ការពារធម្មជាតិទូទាំងប្រទេស**

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- យោងសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ១.**- បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd នៅខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិ តាមខេត្ត ក្រុងពាក់ពន្ធ័ផ្សេងទៀត ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តម **សុខ ចិន្តា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម **ទៅ សុវណ្ណ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤- ឯកឧត្តម **ឆាន់ សារ៉ាវ៉ាន** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥- ឯកឧត្តម **ឌីក គ្រឿនវុទ្ធា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធានប្រចាំការ |
| ៦- ឯកឧត្តម **ស្វរ ទិចន់** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **លឹម សូគុន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- ឯកឧត្តម **ម៉ុល លឹម** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ១០- ឯកឧត្តមឧត្តមសេនីយ៍ទោ **ឡោក់ សិទ្ធិ** | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១- តំណាងមេធាវីរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០១ រូប | | សមាជិក |
| ១២- ឯកឧត្តមអភិបាល ខេត្ត ក្រុង ដែលពាក់ព័ន្ធ នឹងតំបន់ការពារធម្មជាតិ | | សមាជិក |
| ១៣- លោកវរៈសេនីយ៍ឯក **ទ្រាំ ឧុចបូរ៉ាឌឿន** | តំណាងអគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៤- លោក **មួន ហ៊ីងសុធីយ៉ា** | តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១៥- អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | | ជា លេខាធិការដ្ឋាន |

**ប្រការ២.**- គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី ភារកិច្ច និងបេសកកម្មដូចតទៅ:

១- ធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

២- ចូលរួមពិភាក្សា ផ្តល់យោបល់ លើការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

៣- ចូលរួមពិភាក្សា ផ្តល់យោបល់ និងដោះស្រាយលើរាល់ទម្រង់ប័ណ្ណសម្គាល់កម្មសិទ្ធិ និងលិខិតពាក់ព័ន្ធនឹងការកាន់កាប់ប្រើប្រាស់ដីធ្លីក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និងគម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

៤- លើកវិធានការទប់ស្កាត់ និងដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យ ដែលកើតមានឡើងក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd. និង គម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស

៥- បូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការចុះពិនិត្យ សិក្សា សម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន UNION Development Co., Ltd និង គម្រោងវិនិយោគអភិវឌ្ឍន៍ក្នុងតំបន់ការពារធម្មជាតិទូទាំងប្រទេស ។

**ប្រការ៣.-** បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង ដែលតំណាងឱ្យក្រសួង ស្ថាប័ន ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខណ្ឌសមត្ថកិច្ច ភារកិច្ច ដែលបានចែងក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីបូកសរុបលទ្ធផលការងារដែលសម្រេចបានជូនរាជរដ្ឋាភិបាល ។

**ប្រការ៤.-** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្នុងក្រសួងបរិស្ថាន ។

**ប្រការ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការនគរបាលជាតិ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង ដូចមានចែងក្នុងប្រកាស១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ "ដើម្បីជូនជ្រាប និងអនុវត្ត"
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ០២ . សរណន

## សារាចរណែនាំ
## ស្តីពីវិធានការធានាស្ថេរភាព បរិមាណម្ហូបអាហារនៅលើទីផ្សារ និងការនាំចេញស្រូវ-អង្ករ នៅក្រៅប្រទេស

កន្លងមក វិបត្តិហិរញ្ញវត្ថុសកលលោក បានជះឥទ្ធិពលមកលើថ្លៃទំនិញនៅលើទីផ្សារសកលលោក និងបង្កឱ្យមានអស្ថេរភាពដល់ផលិតកម្មស្បៀងអាហារ និងជីវភាពរស់នៅរបស់ប្រជាជននៅបណ្តាប្រទេសក្រីក្រ ដែលរួមមានទាំងកម្ពុជាផងដែរ។ ដើម្បីបង្កើនតម្លៃបន្ថែមដល់ការផលិត-កែច្នៃស្បៀងអាហារក្នុងស្រុក ធានាសុវត្ថិភាពស្បៀងអាហារ និងលើកទឹកចិត្តដល់កសិករ ក្នុងការនាំចេញអង្ករ-ស្រូវទៅក្រៅប្រទេស រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការដូចខាងក្រោម :

១.- ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) ពិនិត្យ និងរៀបចំសម្រួលកាត់បន្ថយនីតិវិធីសម្រាប់ការនាំចេញអង្ករឱ្យបានជាអតិបរមា ដោយធ្វើយ៉ាងណាឱ្យការនាំចេញអង្ករប្រព្រឹត្តិទៅដោយសេរី និងរលូន។

២.- ក្រសួងពាណិជ្ជកម្ម គប្បីសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការគ្រប់គ្រងការនាំចេញស្រូវទៅក្រៅប្រទេសឱ្យបានល្អ ដោយអនុញ្ញាតឱ្យក្រុមហ៊ុន សមាគមន៍ ឬកសិករអាចនាំចេញជាលក្ខណៈគ្រួសារ ក្នុងបរិមាណយ៉ាងច្រើនបំផុត ២០០តោន ក្នុងមួយថ្ងៃ ឬ ១៤០០តោន ក្នុងមួយសប្តាហ៍ ក្នុងមួយក្រុមហ៊ុន ដោយពុំចាំបាច់សុំការអនុញ្ញាតនាំចេញឡើយ។ ក្នុងករណីមានតម្រូវការនាំចេញលើសពីនេះ ក្រុមហ៊ុននាំចេញត្រូវសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម តាមរយៈក្រុមហ៊ុន ហ្គ្រីនត្រេត (Green Trade) ។

៣.- អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់មន្ត្រីឱ្យកត់ត្រាបរិមាណ និងប្រភេទស្រូវ-អង្ករ នាំចេញ-នាំចូលតាមច្រកព្រំដែនផ្លូវការ ឱ្យបានច្បាស់លាស់ ហើយរាយការណ៍មកសាមីប្រធានស្ថាប័នជារៀងរាល់ខែ។

៤.- អាជ្ញាធរដែនដី និងអគ្គស្នងការនគរបាលជាតិ ត្រូវមានវិធានការទប់ស្កាត់ រាល់ការនាំចេញស្បៀងតាមរបៀងលួចលាក់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង (តាមករណីពាក់ព័ន្ធ) ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទការល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ខេត្ត ក្រុង
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៩១៥ ពណ.ចបព

ភ្នំពេញថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គ្រេន ហ្គោលដេន**
**GRAND GOLDEN Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12372/08P ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ហោ ឡឹម** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ត្រាន់ តូហា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០០,០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១១៦ ផ្លូវលេខ ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -[illegible] ទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ ...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៤១៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមបូស៊ែន**

CAMBOSAND Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5108/08E ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក TEO DJIN HIN ប្រធានក្រុមប្រឹក្សាភិបាល

លោក KOH CHUNG WAI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១២៨ H មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ញើ និងផ្ញើកញ្ចប់ទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៩១៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ធនាគារ " អូ អេស ខេ ឥណ្ឌូចែណា "**

**OSK INDOCHINA BANK LIMITED**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5082/08E ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក NIK MOHAMED DIN " តតីយជន " ប្រធានក្រុមប្រឹក្សាភិបាល

លោក ABDUL MAJIT BIN AHMAD KHAN " តតីយជន " អភិបាល

លោក FOO SAN KAN " តតីយជន " អភិបាល

លោក WOON CHONG BOON " តតីយជន " អភិបាល

លោក LEONG YENG KIT " តតីយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១៣.000.000 ដុល្លារអាមេរិក

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៦៣ ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ការទទួលប្រាក់បញ្ញើពីសាធារណជន

-ប្រតិបត្តិការឥណទាននូវវត្ថុដែលអាចទូទាត់ជាសាច់ប្រាក់ រួមមានការជួលអចលវត្ថុ ការទូទាត់ប្រាក់ ថ្លៃទិញលក់ ឬសេវា ប្រាក់កម្ចីប័ណ្ណឥណទាន និងទំរង់ហិរញ្ញប្រទានផ្សេងៗ សមាសធាតុ និងយថាហេតុ

-ការផ្តត់ផ្គង់នូវសេវាទូទាត់ប្រាក់ជូនអតិថិជន និងដំណើរការទូទាត់ជារូបិយប័ណ្ណបរទេស និង/ឬក្នុងស្រុក ដោយរួមបញ្ចូលទាំងការសម្របសម្រួលការទូទាត់ជាមូលប្បទានប័ត្រ

-ការអនុវត្តនូវប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេស ទាំងនៅក្នុងគណនីផ្ទាល់របស់ធនាគារ និងគណនីរបស់អតិថិជន

-ការចូលរួមក្នុងសកម្មភាពទីផ្សារប្រាក់ និងទីផ្សារអន្តរធនាគារ សំរាប់ប្រតិបត្តិការរូបិយប័ណ្ណបរទេស ឬក្នុងស្រុក

-ការចូលរួមនិងបង្កើតទីផ្សារបន្ទាប់សំរាប់ឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមបញ្ចូលទាំងប័ណ្ណប្រាក់រដ្ឋ ឬប័ណ្ណប្រាក់រតនាគារ

-ការធ្វើពាណិជ្ជកម្ម និងគ្រប់គ្រងលើមូលប័ត្រក្នុងស្រុក មូលប័ត្របរទេស និងមូលប័ត្រ អន្តរជាតិ

-ការធានាលើការទិញមូលប័ត្រ

-សកម្មភាពគ្រប់គ្រងមូលនិធិ

-ការចូលរួមក្នុងការចេញ ប័ណ្ណបំណុល ប័ណ្ណបន្ទុក និងឧបករណ៍ដែលអាចទូទាត់បានដទៃទៀត

-វិក័យប័ត្រការប្រាក់ សេវាកម្រៃជើងសារ កម្រៃទាំងឡាយ ដែលអាចនឹងព្រមព្រៀងដោយ គិតពីការផ្តល់ឧបករណ៍ឥណទាន ការធានា ការធានារ៉ាប់រង ឬសេវាធនាគារដទៃផ្សេងទៀត

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រង មុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ស.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៩៤០ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំរាបមក**

លោកប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន " UAS PHARMACEUTICALS PTY LTD. "

អាស័យដ្ឋាន : 15 Cansdale Place, Castle Hill, NSW 2154 Australia.

**កម្មវត្ថុ** : ករណីសុំបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **យូ អេ អេស ហ្វាម៉ាស៊ូធីខល ភីធីវ៉ាយ អិលធីឌី** " Representative Office of " UAS PHARMACEUTICALS PTY LTD. " ប្រចាំព្រះរាជាណាចក្រកម្ពុជា

**យោង** : សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៨

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **យូ អេ អេស ហ្វាម៉ាស៊ូធីខល ភីធីវ៉ាយ អិលធីឌី** " Representative Office of " UAS PHARMACEUTICALS PTY LTD. " ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅប្រទេស អូស្ត្រាលី មានលោក SETH AJIT KUMAR កាន់លិខិតឆ្លងដែន លេខ E 7599092 ចុះថ្ងៃទី 28 - 10 - 2002 ជានាយកតំណាង និងមានទីស្នាក់ការ តាំងនៅ ផ្ទះលេខ ១០ B ផ្លូវលេខ ៣១៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

រាល់សកម្មភាពរបស់ការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុននេះ ត្រូវគោរពប្រតិបត្តិទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការការិយាល័យតំណាងក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អាស្រ័យហេតុនេះ សូមលោកជ្រាបនិងអនុវត្តតាមការសមស្រប ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន** :

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ - កាលប្បវត្តិ

ស.ផ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៩៤១ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៤ ខែ… ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមខូ ស្ពេសល អេខូណូមិក ហ្សូន**

**CAMKO SPECIAL ECONOMIC ZONE Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12331/08P** ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ទិញ ហ៊ីរ** " តតីយជន " ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ហ៊ី ឆេងសៀង** " តតីយជន " អភិបាល

លោក CHA HYO JOON " តតីយជន " អភិបាល

លោក JEONG KI DO " តតីយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦ ផ្លូវលេខ ៤១៦ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៩៤៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វីលលេម៉ា ហូលឌីង ខូ អិលធីឌី**

**WILLEMMA HOLDINGS CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12362/08P** ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **JOHN WILLIAM GURNEY**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៥ វិថីព្រះសុរាម្រិត សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង និង អភិវឌ្ឍន៍ ចលនៈ និង អចលនទ្រព្យ ។

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ថែរក្សាទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

កឹម ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៨៤៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អូផិន វ៉ាញ ម៉ាឃីត**

**OPEN WINE MARKET CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 5095/08E** ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **Philippe H. G. Veeckmans** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ហ្សង់ ម៉ាកឡូម៉េ** អភិបាល

លោក **Frank Didier Volmar Sampere** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២១៩ ផ្លូវលេខ ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណទំនិញគ្រប់ប្រភេទ រាប់ទាំងចំណីអាហារ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មស្របច្បាប់ ដែលពាក់ព័ន្ធនឹងកម្មវត្ថុអាជីវកម្ម ដែលបានពោលខាងលើ ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**កិម ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

  ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

  ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៩៤៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ីកទីណូស ខូ អិលធីឌី**

**IKTINOS CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 12361/08P** ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **RORY MARTIN HUNTER** " តតិយជន " ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **MELITA SARAH KOULMANDAS HUNTER** " តតិយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១០៨ E1 ផ្លូវលេខ ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការដំឡើងផ្គុំសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង វិនិយោគលើចលនៈ និង អចលនៈទ្រព្យ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន ៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ